# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ០៧៤ ប្រក កសក

## ប្រកាស

## ស្ដីពី

## ការដាក់ឱ្យប្រើប្រាស់គំរូសៀវភៅនាវានេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស្រ្តសាស្រ្ត និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

## ស ម្រេ ច

**ប្រការ ១** : ដាក់ឱ្យប្រើប្រាស់គំរូសៀវភៅនាវានេសាទក្នុងគោលបំណងដើម្បីគ្រប់គ្រង និងតាមដានសកម្មភាពនាវានេសាទដែលធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទ។ សៀវភៅនាវានេសាទមានភ្ជាប់ជាមួយក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២** : នាវានេសាទគ្រប់ប្រភេទមានចំណុះផ្ទុកលើសពី ៥០០ គ.ក្រ ដែលធ្វើអាជីវកម្មនេសាទ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងសៀវភៅនាវានេសាទ ដើម្បីធានាសុវត្ថិភាពសណ្ដាប់ធ្នាប់ចរាចរ និងអាយុជីវិតអ្នកនេសាទ ។

អាស័យដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N°.200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D. Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១/២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 – 217 320

**ប្រការ៣** : គំរូសៀវភៅនាវានេសាទមានក្របពណ៌ខៀវខ្ចី និងស្លាកសញ្ញាជលផលកម្ពុជា មានអង្កត់ផ្ចិតប្រវែង ១១០ មម ។ សៀវភៅនាវានេសាទ ត្រូវបានផ្ដល់ជូនដោយឥតគិតថ្លៃពីរដ្ឋបាលជលផល ។

**ប្រការ ៤** : អ្នកបើកបរនាវានេសាទ ត្រូវរក្សាទុកសៀវភៅនាវានេសាទឱ្យបានគង់វង្ស មិនរហែក ឬបាត់បង់សន្លឹកឡើយ ហើយត្រូវបង្ហាញដល់ភ្នាក់ងារជលផលមានសមត្ថកិច្ចនៅរាល់ពេលត្រួតពិនិត្យ ។ ក្នុងករណីបាត់បង់ អ្នកបើកបរនាវានេសាទត្រូវរាយការណ៍ជាបន្ទាន់ជូនសមត្ថកិច្ចជលផល ដើម្បីស្នើសុំសៀវភៅនាវានេសាទជាថ្មី ។

**ប្រការ ៥** : ជនណាដែលក្លែងបន្លំសៀវភៅនាវានេសាទ ឬប្រព្រឹត្តផ្ទុយនឹងខ្លឹមសារដែលមានចែងក្នុងប្រកាសនេះ ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៦** : ប្រកាស ឬសេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានរដ្ឋបាលជលផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

**ចាន់-សារុន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
- ដូចប្រការ ៧ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ